# ទស្សនាវដ្តី កសិកម្ម

# THE AGRICULTURE MAGAZINE



ឆ្នាំទី ២០ ត្រីមាសទី ២ (មេសា-មិថុនា) ឆ្នាំ ២០២១ លេខ ៧៨

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh

# មាតិកា

ទំព័រ

- ព្រះរាជសារ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ០១
- ព្រះរាជសារ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ០២
- ព្រះរាជសារ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា** ជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ០៣
- សុន្ទរកថាឯកឧត្តម **វេង សាខុន**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម........ ០៤
- ជំនួយស្មារតីឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ និងមាន់សាច់ក្នុងកម្មវិធី ASPIRE........ ១០
- ដំណាំមន........ ១៦
- ចំណេះដឹងស្តីអំពីសុខភាពសត្វ(បន្តពីទស្សនាវដ្តីកសិកម្ម លេខ៧៧) ........ ៣០
- បច្ចេកទេសដាំដំណាំកៅស៊ូជាលក្ខណៈគ្រួសារ (បន្តពីទស្សនាវដ្តីកសិកម្មលេខ៧៧)........ ៣៨
- ការគ្រប់គ្រងព្រៃប្រកបដោយនិរន្តរភាពតាមរយៈយន្តការរេនបូកនៅខេត្តកំពង់ធំ........ ៤៤
- របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆមាសទី១ ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត........ ៤៦
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ៦១

# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ
# នរោត្តម សីហមុនី
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម **វេង សាខុន**
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម ជាទីរាប់អានដ៏ខ្ពង់ខ្ពស់

ខ្ញុំបានទទួលរួចហើយនូវលិខិតរបស់ឯកឧត្តម ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ដែលបានថ្វាយសព្ទសាធុការពរជ័យ ចំពោះខ្ញុំ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ឆ្នាំ២០២១ ។

ខ្ញុំសូមអរគុណ និងសូមប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការ នៅក្នុងទិវាដ៏នក្ខត្តឫក្ស នៃបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំឆ្លូវ ដ៏ឧត្តុង្គឧត្តមនេះ សូម ឯកឧត្តម ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងព្រះពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម ឯកឧត្តម ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២១

# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ
# នរោត្តម សីហមុនី
# ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូន ឯកឧត្តម **វេង សាខុន**
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម ជាទីរាប់អានដ៏ខ្ពង់ខ្ពស់

ខ្ញុំបានទទួលរួចហើយនូវលិខិត ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់ឯកឧត្តម ដែលបានថ្វាយសព្ទសាធុការពរចំពោះខ្ញុំ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនជន្មាយុ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ។

ខ្ញុំសូមអរគុណ និងសូមកោតសរសើរចំពោះឯកឧត្តម និងសហការីទាំងអស់ ដែលបានចូលរួមអនុវត្តតាមវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានល្អប្រសើរ ។

ខ្ញុំសូមជូនពរ ឯកឧត្តម ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងព្រះពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២១

**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា**
**នរោត្តម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន ឯកឧត្តម វេង សាខុន
រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តម

ខ្ញុំ សូមអរគុណដ៏ជ្រាលជ្រៅ ចំពោះលិខិតថ្វាយព្រះពររបស់ឯកឧត្តម នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥។

សូមជូនពរឯកឧត្តម ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ។

**នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២១

# សុន្ទរកថា
# ឯកឧត្តម វេង សាខុន
# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម

ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

**គណៈអធិបតី**

- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ
- សមាជិក សមាជិកា នៃអង្គពិធីទាំងមូលជាទីមេត្រី!



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

ជាបឋមក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ព្រមទាំងសមាជិក សមាជិកានៃអង្គពិធីទាំងមូលដែលបានអញ្ជើញចូលរួមក្នុង ពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម នាពេលនេះ។

ប្រាកដណាស់ថា កិច្ចប្រជុំបូកសរុបដែលបានប្រព្រឹត្តទៅអស់រយៈពេល ២ថ្ងៃមកនេះ មិនត្រឹមតែជាឱកាសមួយសម្រាប់យើងទាំងអស់គ្នាចូលរួមពិភាក្សាចែករំលែកទស្សនៈ និងផ្តល់នូវធាតុចូលជាគំនិតថ្មីៗ លើលទ្ធផលការងារ កាលានុវត្តភាព និងបញ្ហាប្រឈមផ្សេងៗដែលយើងបានជួបប្រទះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឱកាសសម្រាប់យើងទាំងអស់គ្នាបូកសរុប និងវាយតម្លៃលើសមិទ្ធផលដែលយើងសម្រេចបានក្នុងឆ្នាំកន្លងមក ព្រមទាំងរិះរកគ្រប់មធ្យោបាយ ដើម្បីកំណត់បណ្តាសកម្មភាព ជាអាទិភាពឈានឆ្ពោះទៅរកការអភិវឌ្ឍវិស័យកសិកម្មឱ្យមានការរីកចម្រើនឆាប់រហ័ស និងប្រកបដោយចីរភាព។ ជាពិសេសនៅក្នុងបរិការណ៍មួយដែលប្រទេសជាតិយើងកំពុងខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ក្រោយពីវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់កន្លងមកនេះ។



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

**អង្គពិធីទាំងមូលជាទីមេត្រី!**

បច្ចុប្បន្ននេះ ការរាតត្បាតនៃជំងឺកូវីដ-១៩ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបាននាពេលកន្លងមកដោយលំបាកប៉ុណ្ណោះទេ តែថែមទាំងអាចបន្ថយបង្អាក់ដល់កិច្ចដំណើរការអភិវឌ្ឍឈានឡើងរបស់កម្ពុជា ពិសេសអាចនឹងពន្យារពេល នៃការឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជា ក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ផងដែរ។ ប្រាកដណាស់ថាវិបត្តិជំងឺកូវីដ-១៩នេះ នឹងបញ្ចប់នៅពេលណាពិតប្រាកដនោះឡើយ ហើយក៏គ្មាននរណាអាចទស្សន៍ទាយ និងវាយតម្លៃអំពីផលប៉ះពាល់មកលើគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅរបស់សង្គមជាតិនីមួយៗបានជាក់ច្បាស់នោះដែរ។ ជាបច្ច័យ ស្ថានភាពនៃកំណើនសេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំ២០២០នេះ ត្រូវបានព្យាករណ៍ថា មានភាពថមថយដល់កម្រិតទាបបំផុតគិតចាប់តាំងពីសង្គ្រាមលោកលើកទី២មក។

គួរកត់សម្គាល់ថា តាមទិន្នន័យនៃការជំរឿននាពេលថ្មីៗនេះ បានបង្ហាញថា ប្រជាជនប្រមាណជា ៥៤,៧% នៃប្រជាជនកម្ពុជាធ្វើការក្នុងវិស័យទី១ (កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) បន្ទាប់មក គឺវិស័យការងារទី៣(សេវាកម្ម) មានអត្រា ២៦,៥% ហើយចុងក្រោយគឺវិស័យការងារទី២ (ឧស្សាហកម្ម)មានអត្រា១៨,៨%។ វិស័យការងារទាំង៣នេះសម្រាប់ឆ្នាំ២០០៨ មានក្នុងអត្រា ៧២,៣% ១៩,២% និង៨,៥%។ យើងសង្កេតឃើញថា ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មនៅឆ្នាំ១៩៩៨ ស្មើនឹង ៧៧,៥% បានធ្លាក់ចុះមកនៅត្រឹម ៧២,៣% នៅឆ្នាំ២០០៨ និងធ្លាក់ចុះ ៥៤,៧% នៅជំរឿនឆ្នាំ២០១៩។ ទិន្នន័យនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅរកវិស័យឧស្សាហកម្មជាបន្តបន្ទាប់នា រយៈពេលចុងក្រោយនេះ ពិសេសស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។

ដូចខ្ញុំបានរំឭកជាហូរហែរួចមកហើយថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ គឺមានគោលដៅពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ដោយបានកំណត់ច្បាស់នូវចក្ខុវិស័យក្នុងក្របខណ្ឌកំណែទម្រង់ស៊ីជម្រៅ ដើម្បីប្រែក្លាយកសិកម្មកម្ពុជាឱ្យមានលក្ខណៈទំនើប ប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា តាមរយៈការបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយធានាបាននូវការអភិវឌ្ឍ និងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាព។

លើសពីនេះទៀត អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងបាននឹងកំពុងជំរុញបន្ថែមដល់សហគមន៍ កសិករ ផលិតករ



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*



*ឯកឧត្តម ងិន ឆាយ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយដ្ឋានកសិកម្ម អញ្ជើញអានរបាយការណ៍បូកសរុបក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

ខ្នាតតូច និងមធ្យម សហការធ្វើការដាំដុះ ចិញ្ចឹមសត្វ និងត្រីជាមួយវិស័យឯកជន តាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យា ដើម្បីធានាបាននូវបរិមាណផ្គត់ផ្គង់ទីផ្សារ និងស្ថិរភាពតម្លៃ ព្រមជាមួយការលើកទឹកចិត្ត ជំរុញគាំទ្រវិស័យឯកជន សហគ្រាសខ្នាតតូច មធ្យម និងដៃគូអភិវឌ្ឍន៍នានា វិនិយោគលើវិស័យកែច្នៃ ដើម្បីធានានូវនិរន្តរភាពនៃការផលិតក្នុងស្រុក ស្ថិរភាពទីផ្សារ បង្កើនតម្លៃបន្ថែម លើកកម្ពស់គុណភាពស្តង់ដារអនាម័យ និងសុវត្ថិភាពឆ្លើយតបតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យ របស់ទីផ្សារទាំងក្នុងតំបន់ និងអន្តរជាតិ។

ទោះជាយ៉ាងណា វិស័យកសិកម្ម ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងក្នុងអត្រា១,៦% ក្នុងឆ្នាំ២០២១ ពីកំណើន ០.៩% ក្នុងឆ្នាំ២០២០ ដោយសារការកើនឡើងនៃអនុវិស័យដំណាំ អនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ។ ដោយឡែក អនុវិស័យដំណាំត្រូវបានព្យាករណ៍ថានឹងសម្រេចបានកំណើនខ្ពស់ជាងឆ្នាំ២០២០ ដោយសារការរំពឹងទុកនូវកំណើនផលិតកម្មកសិកម្ម ស្របពេលដែលថ្លៃ និងតម្រូវការខាងក្រៅមានការកើនឡើង។ ជាមួយគ្នាផងដែរ អនុវិស័យចិញ្ចឹមសត្វត្រូវបានព្យាករណ៍ថា នឹងបន្តកំណើនវិជ្ជមានគាំទ្រដោយការរំពឹងទុកនូវកំណើនការចិញ្ចឹមសត្វបែបពាណិជ្ជកម្ម ពិសេសការចិញ្ចឹមជ្រូកដែលជំរុញដោយភាពល្អប្រសើរនៃថ្លៃសាច់ជ្រូក។ ទន្ទឹមនេះ អនុវិស័យនេសាទ ត្រូវបានព្យាករណ៍ថា នឹងមានកំណើនខ្ពស់ជាងឆ្នាំ២០២០បន្តិច ដែលត្រូវបានជំរុញដោយកំណើនល្អនៃអនុវិស័យវារីវប្បកម្ម។ ទោះជាយ៉ាងណា យើងក៏ទទួលស្គាល់ថា ក្នុងបរិបទនៃការជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីវិបត្តិជាសកលបណ្តាលមកពីហានិភ័យនៃជំងឺកូវីដ-១៩ ក៏ដូចជាការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត ទឹកជំនន់ជាដើមនោះ បានធ្វើឱ្យវិស័យកសិកម្ម យើងជួបប្រទះបញ្ហាប្រឈមមួយចំនួនមានជាអាទិ៍៖ (១)- ផលិតភាពក្នុងការដាំដុះនៅមានកម្រិតទាបនៅឡើយ ហើយកសិករមួយចំនួនធំធ្វើស្រែមួយដងក្នុងមួយឆ្នាំដោយពុំទាន់ប្រើប្រាស់បច្ចេកទេសទំនើប គ្រាប់ពូជមិនទាន់សុទ្ធល្អ និងធ្វើការដាំដុះពឹងផ្អែកលើរបបទឹកភ្លៀង ដោយសារខ្វះប្រព័ន្ធស្រោចស្រព ដែលមានហានិភ័យខ្ពស់ចំពោះការទទួលបានផលិតផលតាមការរំពឹងទុក។ (២)-ធាតុចូលកសិកម្ម ដូចជាជីគីមី និងថ្នាំកសិកម្មត្រូវបាននាំចូលពីបរទេសដែលមានតម្លៃថ្លៃ ហើយថ្លៃប្រេងនិងអគ្គិសនីខ្ពស់ដែលធ្វើឱ្យថ្លៃផលិតកម្មខ្ពស់។ បញ្ហាតម្លៃដឹកជញ្ជូន និងប្រព័ន្ធសេវាភស្តុភារ មិនទាន់គ្រប់គ្រាន់ធ្វើឱ្យមានតម្លៃខ្ពស់ មិនអាចប្រកួតប្រជែងជាមួយផលិតផលកសិកម្មពីបរទេស។ (៣)- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការផ្សព្វផ្សាយបច្ចេកទេស និងការផ្តល់សេវាព័ត៌មានទីផ្សារកសិផលទៅដល់កសិករនៅមិនទាន់បានទូលំទូលាយនៅឡើយ។ ផលិតកម្មដំណាំកសិកម្មបានទទួលផលប៉ះពាល់ជាអវិជ្ជមានដោយគ្រោះរាំងស្ងួត ទឹកជំនន់ ដង្កូវហ្វូង និងជំងឺម៉ូសាអ៊ិកលើដំណាំដំឡូងមី។ (៤)- ការសិក្សាស្រាវជ្រាវលើបច្ចេកទេសដាំដុះ ការបន្សុទ្ធពូជ ការគ្រប់គ្រងទឹក និងជីជាតិដី និងវិធានការកម្ចាត់សមាសភាពចង្រៃនៅមានកម្រិត ហើយស្ថានីយពិសោធន៍ស្រាវជ្រាវកសិកម្មនៅពុំទាន់បំពេញតួនាទីបានល្អប្រសើរ ដោយខ្វះមន្ត្រីបច្ចេកទេស



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

និងហេដ្ឋារចនាសម្ព័ន្ធបម្រើការងារពិសោធន៍ស្រាវជ្រាវ។ (៥)-សមត្ថភាពបច្ចេកទេស បទដ្ឋានគតិយុត្តនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការងារអនាម័យ និងភូតគាមអនាម័យ មិនទាន់កសាងបានគ្រប់គ្រាន់ដើម្បីធានាគុណភាព និងសុវត្ថិភាពកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុក និងការនាំចេញ។ (៦)- សមត្ថភាពរបស់សហគមន៍កសិកម្ម ដែលបានបង្កើតក្នុងគោលបំណងបង្កើនអំណាចតថ្លៃ ការទទួលបានសេវាបច្ចេកទេស និងឥណទានត្រូវបានវាយតម្លៃថានៅមានកម្រិត។ កសិករតែងជួបប្រទះនូវការធ្លាក់ចុះនៃតម្លៃកសិផលនៅពេលប្រមូលផលដោយសារផលិតផលមិនទាន់ស្របតាមតម្រូវការស្តង់ដារទីផ្សារទាំងស្រុង ការអនុវត្តផលិតកម្មតាមកិច្ចសន្យានៅពុំទាន់បានល្អប្រសើរ និងការស្វែងរកទីផ្សារមិនទាន់បានគ្រប់ជ្រុងជ្រោយ។ (៧)-ការប្រមូលទិន្នន័យនៅមិនទាន់មានភាពសុក្រឹតល្អ ជាពិសេសផលិតកម្មដំណាំរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងទិន្នន័យការនាំចេញកសិផលគ្មានវិញ្ញាបនបត្រភូតគាមអនាម័យនៅតាមបណ្តាខេត្តជាប់ព្រំដែន។

ឆ្លើយតបទៅនឹងមូលបញ្ហាដូចបានរៀបរាប់ខាងលើ អង្គប្រជុំក៏បានកំណត់នូវទិសដៅ និងវិធានការថ្មីៗទៀតសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២១ ដើម្បីធានាដល់ការគ្រប់គ្រង និងអភិវឌ្ឍវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ដូចដែលបានរៀបរាប់លម្អិតនៅក្នុងរបាយការណ៍របស់ឯកឧត្តម **ងិន ឆាយ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នៅមុននេះបន្តិច។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់លើលទ្ធផលបូកសរុបការងារឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម ដែលសម្រេចបានសមិទ្ធផលដ៏ល្អប្រសើរនេះ កើតចេញពីការខិតខំប្រឹងប្រែងយ៉ាងសកម្មអស់ពីកម្លាំងកាយចិត្ត គំនិតប្រាជ្ញាប្រកបដោយភាពច្នៃប្រឌិត និងមានសាមគ្គីភាពផ្ទៃក្នុងបានល្អរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់តាមអភិក្រម **"រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍"** ដែលខ្ញុំសូមចូលរួមអបអរសាទរនូវសមិទ្ធផល ដែលសម្រេចបានជាវិជ្ជមាននេះ ពិតមែនតែយើងនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។

អនុលោមតាម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ពិសេសឆ្លើយតបនឹងបញ្ហាប្រឈមខាងលើនេះ ក្នុងទិសដៅពង្រីកកំណើនអនុវិស័យដំណាំកសិកម្មឱ្យកាន់តែល្អប្រសើរប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីដើរតាមឱ្យទាន់ទៅនឹងការវិវឌ្ឍន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ ផ្សារភ្ជាប់ទៅនឹងចំណុចគន្លឹះដែលខ្ញុំបានលើកឡើងកាលពីឆ្នាំ២០២០ កន្លងទៅនោះ ខ្ញុំសូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដើម្បីជាមូលដ្ឋានអនុវត្តបន្តដូចតទៅ៖

**ទី១.** ត្រូវរៀបចំ និងពង្រឹងអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិ ដែលបម្រើឱ្យការងារគ្រប់គ្រងផលិតកម្មដំណាំ ការត្រួតពិនិត្យគុណភាព ជាពិសេសជំរុញការបញ្ចប់ការរៀបចំច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍លើដំណាំសំខាន់ៗ រួមមាន បន្លែ ចេក ស្វាយ ស្វាយចន្ទី ពោត កសិកម្មសរីរាង្គ ។ល។ ទន្ទឹមនឹងនេះ ក៏មិនត្រូវមើលរំលងអំពីការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង ដឹកនាំ និងអាជីវកម្មរបស់សហគមន៍កសិកម្មឱ្យមានលក្ខណៈអាជីពក្នុងធុរកិច្ចកសិកម្ម និងសហការជាមួយវិស័យឯកជន ដើម្បីអភិវឌ្ឍខ្សែច្រវាក់តម្លៃលើមុខដំណាំសំខាន់ៗ តាមរយៈការគាំទ្រហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដូចជាផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព ឃ្លាំង និងទីផ្សារ។ល។ សម្របសម្រួលជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា ក្នុងការទទួល



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម*

បានទុនជាមួយនឹងការប្រាក់សមរម្យ។ ជាមួយនេះ ក៏ត្រូវគិតគូរអំពីការចងក្រងសហគមន៍ដែលមានសក្តានុពលឱ្យក្លាយទៅជាសហគមន៍ទេសចរណ៍ប្រកបដោយភាពទាក់ទាញផងដែរ ព្រមទាំងត្រូវជំរុញឱ្យមានការបង្កើតច្រើនឡើងថែមទៀតនូវ "សហគ្រិនភាពកសិកម្មថ្មីៗ -Agri-Entrepreneurship Incu-bators" ដើម្បីការរីកលូតលាស់កសិកម្មប្រកបដោយប្រសិទ្ធភាព និងបរិយាប័ន្ន។

ទី២. ត្រូវជំរុញការសិក្សាស្រាវជ្រាវបច្ចេកទេសផលិតកម្មដំណាំបន្សុទ្ធ និងពង្រីកពូជដំណាំដែលមានគុណភាពល្អធន់នឹងការប្រែប្រួលអាកាសធាតុ និងតម្លៃបន្ថែមខ្ពស់ នៅតាមស្ថានីយពិសោធន៍ស្រាវជ្រាវតាមសហគមន៍កសិកម្ម និងការលើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមវិនិយោគក្នុងការផលិតពូជដំណាំ ដែលមានគុណភាពខ្ពស់ស្របតាមស្តង់ដារ និងតម្រូវការទីផ្សារដើម្បីធ្វើឱ្យមានបរិមាណគ្រប់គ្រាន់ និងតម្លៃសមរម្យសម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម។ ទន្ទឹមនឹងនេះ ត្រូវជំរុញការផលិតបន្លែ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មឱ្យមានគុណភាពល្អ និងសុវត្ថិភាពដែលអាចជំនួសការនាំចូល និងបម្រើការនាំចេញ ដោយប្រើប្រាស់ស្តង់ដារការអនុវត្តកសិកម្មល្អប្រកបដោយភាពវៃឆ្លាត តាមរយៈការអនុវត្តផលិតកម្មតាមកិច្ចសន្យា ការពង្រីកទីផ្សារប្រមូលផ្តុំ បោះដុំ និងចែកចាយឱ្យបានទូលំទូលាយ។

ទី៣. ត្រូវគិតគូរអំពីការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្មក្នុងការវិភាគ និងវាយតម្លៃគុណភាពធាតុចូលកសិកម្ម (ពូជ ជី ថ្នាំកសិកម្ម) គុណភាពដី ទឹក និងកម្រិតសំណល់ថ្នាំកសិកម្មក្នុងផលិតផលកសិកម្ម ដោយត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ ដើម្បីឱ្យមានការទទួលស្គាល់ជាលក្ខណៈស្តង់ដារ ISO។ ទន្ទឹមនឹងនេះ ក៏ត្រូវលើកកម្ពស់ការគ្រប់គ្រងធនធានដីកសិកម្ម ដោយជំរុញការសិក្សាវាយតម្លៃគុណភាពដី ការធ្វើផែនទីតំបន់ដាំដុះទៅតាមប្រភេទដី និងមុខដំណាំ ការអនុវត្តវិធានការចម្រុះគ្រប់គ្រងជីជាតិដី និងការរៀបចំយុទ្ធសាស្ត្រផ្លាស់ប្តូរមុខដំណាំ ព្រមទាំងត្រូវពង្រឹង និងពង្រីកផ្នែកវិស្វកម្មកសិកម្ម និងយន្តូបនីយកម្មកសិកម្ម តាមរយៈការស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា និងឧបករណ៍សម្ភារ បច្ចេកវិទ្យាក្រោយពេលប្រមូលផល ប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកសម្រាប់កសិកម្មប្រកបដោយប្រសិទ្ធភាព។

ទី៤. ត្រូវពង្រឹងវិធានការការពារដំណាំ អនាម័យ និងភូតគាមអនាម័យ តាមរយៈការតាមដានវាយតម្លៃ ព្យា-ករណ៍ និងការអន្តរាគមន៍កម្ចាត់សមាសភាពចង្រៃលើដំណាំ ការត្រួតពិនិត្យ និងចុះបញ្ជីកសិដ្ឋានការអនុវត្តកសិកម្មល្អ ពង្រឹងយន្តការទប់ស្កាត់ការឆ្លងរាលដាលនូវសមាសភាពចង្រៃ និងរឹតបន្តឹងការនាំចូលកសិផលគ្មានគុណភាព និងគ្មានសុវត្ថិភាព ដែលនាំឱ្យប៉ះពាល់ដល់ផលិតកម្មដំណាំក្នុងស្រុក និងសុខភាពប្រជាពលរដ្ឋ។ អគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យស្ថិតិដំណាំកសិកម្មឱ្យគ្រប់ជ្រុងជ្រោយ ជាពិសេសនៅតាមបណ្តាក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច និងការនាំចេញ នាំចូលកសិផលនៅតាមបណ្តាខេត្តជាប់ព្រំដែន ដោយប្រើប្រាស់ទម្រង់ប្រមូលទិន្នន័យថ្មីប្រកបដោយការទទួលខុសត្រូវខ្ពស់។

ទី៥. ជំរុញសេវាត្រួតពិនិត្យភូតគាមអនាម័យឱ្យកាន់តែកៀកនឹងអ្នកប្រើប្រាស់ និងកាន់តែមានភាពងាយ